មជ្ឈមណ្ឌលឯកសារកម្ពុជា



# "តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម"

## ដំណើរទស្សនកិច្ចអគារអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Documentation Center of Cambodia
Searching for the Truth ស្វែងរកការពិត ដើម្បីការចងចាំ និងយុត្តិធម៌

DC-Cam ◆ 66 Preah Sihanouk Blvd. ◆ P.O.Box 1110 ◆ Phnom Penh ◆ Cambodia
Tel: (855-23) 211-875 ◆ Fax: (855-23) 210-358 ◆ dccam@online.com.kh ◆ www.dccam.org

# មជ្ឈមណ្ឌលឯកសារកម្ពុជា

## មាតិកា


- សិទ្ធិរបស់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ............................................១
- សំណងជំងឺចិត្តចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម............................................៧
- សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង............................................១១
- ចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ អេ មូសូមេលី..........................១៥






# សិទ្ធិរបស់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ


**រីឆាត ហ្គីលប៊ឺត**

**ប្រែសម្រួលដោយ ខ៊ាន់ថាន់ ពៅដារ៉ា**


ចាប់តាំងពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩ របបកម្ពុជាប្រជាធិបតេយ្យ ដែលឃោរឃៅនិងព្រៃផ្សៃបានបន្តការឈឺចាប់ទាំងផ្លូវកាយនិងចិត្តចំពោះប្រជាជនកម្ពុជាទូទាំងប្រទេស ។ ក្នុងចន្លោះពេលវេលាខាងលើ មានប្រជាជនកម្ពុជារាប់លាននាក់បានស្លាប់បាត់បង់ជីវិតដោយសារការបង្អត់អាហារ ការខ្វះអាហារទ្រទ្រង់ជីវិត ការធ្វើការហួសកម្លាំង ទារុណកម្ម និងការសម្លាប់ ។ ជនរងគ្រោះដែលនៅរស់រានមានជីវិតសព្វថ្ងៃ នៅមានការឈឺចាប់នៅឡើយចំពោះការគ្រប់គ្រងនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ប្រជាជនស្ទើរតែគ្រប់រូបនៅក្នុងប្រទេសបានក្លាយជាជនរងគ្រោះដោយសាររបបនេះតាមរូបភាពផ្សេងៗគ្នា ។

### តើនរណាខ្លះជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ?

ដោយហេតុថា អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) ចាប់ដំណើរការហើយ ជាការសំខាន់ខ្លាំងណាស់ដែលត្រូវយល់ដឹងថា មានជនរងគ្រោះជាច្រើនប្រភេទផ្សេងៗគ្នា និងជនរងគ្រោះប្រភេទធ្ងន់ធ្ងរ ។ សម្រាប់តុលាការ យើងត្រូវការចាំបាច់ធ្វើបញ្ជីទាក់ទិននឹងប្រភេទជនរងគ្រោះនិងសិទ្ធិមួយចំនួនដែលជនរងគ្រោះត្រូវមាន ។ វាជាការសំខាន់ពីព្រោះថា ជនរងគ្រោះប្រភេទខុសៗគ្នានឹងមានសិទ្ធិខុសៗគ្នានៅចំពោះមុខតុលាការ ។ ប្រជាជនកម្ពុជាដែលជាជនរងគ្រោះត្រូវបានបែងចែកជា៤ប្រភេទខុសៗគ្នាដូចខាងក្រោម ÷

### ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត

ជនរងគ្រោះជាក់ស្តែងជាងគេនៃរបបខ្មែរក្រហមគឺប្រជាជនកម្ពុជាដែលបានស្លាប់បាត់បង់ជីវិតក្រោមរបបនេះរាប់លាននាក់ ។ ដោយសារតែហេតុផលដ៏សំខាន់ដែលថាជនរងគ្រោះត្រូវស្លាប់រាប់លាននាក់នេះហើយ ទើបមានការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ។ ដូច្នេះតុលាការនឹងពិនិត្យមើលលើរឿងក្តីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដើម្បីរកឲ្យ ឃើញថាតើមេដឹកនាំមួយណាជាអ្នកបង្កឲ្យមានការស្លាប់ទាំងអស់នេះ ។

### សមាជិកក្រុមគ្រួសាររបស់ជនរងគ្រោះដែលបានស្លាប់បាត់បង់ជីវិត

ជនរងគ្រោះកម្ពុជាដែលស្លាប់បាត់បង់ជីវិតក្រោមរបបខ្មែរក្រហមបានបន្សល់ទុកនូវសមាជិក

ក្រុមគ្រួសាររបស់ខ្លួនជាច្រើន ហើយអ្នកទាំងអស់នេះនៅរស់រានមានជីវិតនៅឡើយ ។ អ្នកនៅរស់រានមានជីវិតទាំងនេះជួនកាលបានឃើញការសម្លាប់សមាជិកក្រុមគ្រួសាររបស់ខ្លួនដោយផ្ទាល់ភ្នែកក៏មាន អ្នកខ្លះទៀតបានឃើញការចាប់ចងសមាជិកក្រុមគ្រួសាររបស់ខ្លួនដោយផ្ទាល់ភ្នែក ប៉ុន្តែក្រោយមក មិនដែលបានឃើញអ្នកទាំងនោះវិលត្រឡប់មកវិញឡើយ ។ ជួនកាលទៀតខ្មែរក្រហមបានបញ្ជូនសមាជិកក្រុមគ្រួសារខ្លះឲ្យទៅធ្វើការនៅកន្លែងផ្សេងៗពីគ្នា ហើយអ្នកទាំងនោះកម្រដែលឃើញត្រឡប់មកវិញណាស់ ។ សមាជិកគ្រួសារដែលនៅរស់រានមានជីវិតមានទុក្ខសោកជាខ្លាំងដោយសារតែខ្លួនពុំបានដឹងថាអ្នកជាទីស្រឡាញ់របស់ខ្លួនស្លាប់ឬក៏នៅរស់ ។ មានសមាជិកក្រុមគ្រួសារខ្លះដែលដឹងថាអ្នកជាទីស្រឡាញ់របស់ខ្លួនស្លាប់បាត់បង់ជីវិតទៅហើយក៏ដោយ ក៏នៅតែមានទុក្ខសោកដែរ ព្រោះពុំបានដឹងថាអ្នកដែលស្លាប់ទៅនោះស្លាប់យ៉ាងដូចម្តេច ហើយសាកសពមិនដឹងស្ថិតនៅឯណា ។

## ជនគ្រប់រូបដែលមានការឈឺចាប់ក្នុងអារម្មណ៍

ខ្មែរក្រហមបានបន្តការឈឺចាប់ដល់អារម្មណ៍របស់ប្រជាជនកម្ពុជាដែលនៅរស់រានមានជីវិតសព្វថ្ងៃ ។ ការឈឺចាប់ចំពោះរបបកម្ពុជាប្រជាធិបតេយ្យដូចជាការបង្អត់អាហារ ការបង្ខំឲ្យធ្វើការជាទម្ងន់ ទារុណកម្ម និងការសម្លាប់រង្គាលនៅតែបន្តការប៉ះពាល់ដល់អារម្មណ៍របស់ប្រជាជនកម្ពុជាជាច្រើនលាននាក់ដែលនៅតែមានអារម្មណ៍សោកសង្រេងនិងឈឺចាប់ជារៀងរាល់ថ្ងៃដោយសារតែអ្វីដែលបានកើតឡើងកន្លងមក ។

## កម្មាភិបាលខ្មែរក្រហមខ្លួនឯង

វាជាការសំខាន់ដែលត្រូវចងចាំថា កម្មាភិបាលខ្មែរក្រហមមួយចំនួនគឺជាជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យដែរ ។ ឧទាហរណ៍កម្មាភិបាលម្នាក់បានប្រាប់យើងថា ខ្លួនត្រូវតែធ្វើបាបអ្នកដទៃ បើពុំធ្វើដូច្នេះទេនឹងមានកម្មាភិបាលផ្សេងទៀតសម្លាប់គាត់ ឬសម្លាប់ក្រុមគ្រួសាររបស់គាត់ជាជំនួសវិញ ។ កម្មាភិបាលប្រភេទនេះនិងអ្នកផ្សេងទៀតដែលទទួលការបង្ខិតបង្ខំឲ្យចូលរួមជាមួយខ្មែរក្រហម ក៏ជាជនរងគ្រោះដែរ ។

## តើច្បាប់អ្វីខ្លះដែលនឹងត្រូវប្រើប្រាស់នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា?

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម) នឹងប្រើប្រាស់ច្បាប់កម្ពុជាដែលនៅជាធរមាននិងច្បាប់ដែលបង្កើតតុលាការខាងលើ(ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅ





ក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ) ។ ច្បាប់សំខាន់ៗមួយចំនួនដែលហៅថា “ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ” នឹងត្រូវបានយកមកប្រើប្រាស់ដើម្បីកំណត់សិទ្ធិរបស់ជនរងគ្រោះនៅចំពោះមុខតុលាការ ។ សព្វថ្ងៃនេះយើងមាន “ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ” ចំនួន២គឺច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌនៃរបបរដ្ឋកម្ពុជា ឆ្នាំ១៩៩៣ និងច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌដែលបង្កើតឡើងនៅក្នុងសម័យអ៊ុនតាក់ ឆ្នាំ១៩៩២ ។ ច្បាប់ទាំងពីរនេះកំណត់នូវសិទ្ធិរបស់ជនរងគ្រោះនាពេលបច្ចុប្បន្ន ។ នៅមានសេចក្តីព្រាងច្បាប់ថ្មីមួយទៀតគឺ “នីតិវិធីព្រហ្មទណ្ឌ” ដែលរដ្ឋសភាជាតិកំពុងធ្វើការសម្រេចមុននឹងអនុម័តជាផ្លូវការ ។ ប្រសិនបើរដ្ឋសភាជាតិអនុម័តលើសេចក្តីព្រាងច្បាប់នីតិវិធីនេះទៀតច្បាប់នេះនឹងត្រូវយកទៅប្រើប្រាស់ដើម្បីកំណត់អំពីសិទ្ធិរបស់ជនរងគ្រោះចំពោះតុលាការថែមទៀត ។

## តើមានបញ្ហាអ្វីកើតឡើងដែរឬទេ ប្រសិនបើច្បាប់កម្ពុជាពុំបានឆ្លើយតបទៅតាមស្តង់ដារអន្តរជាតិ?

ប្រសិនបើច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជាមិនបានឆ្លើយតបទៅតាមស្តង់ដារអន្តរជាតិ អង្គជំនុំជម្រះវិសាមញ្ញអាចប្រើប្រាស់ច្បាប់អន្តរជាតិដើម្បីធ្វើការសម្រេចសេចក្តី ។ អង្គជំនុំជម្រះវិសាមញ្ញប្រហែលជានឹងមិនប្រើប្រាស់ច្បាប់អន្តរជាតិទេ ពីព្រោះថាច្បាប់កម្ពុជានិងច្បាប់នីតិវិធីព្រហ្មទណ្ឌមើលទៅទំនងជានឹងឆ្លើយតបបានទៅនឹងស្តង់ដារអន្តរជាតិស្តីអំពីសិទ្ធិរបស់ជនរងគ្រោះជាស្រេចទៅហើយ ។

## តើសិទ្ធិអ្វីខ្លះដែលជនរងគ្រោះមាន?

### សិទ្ធិចូលរួម

ជនរងគ្រោះមានសិទ្ធិចូលរួមជាមួយអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាតាមវិធីច្រើនយ៉ាង ។ បើយោងតាមច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ជនរងគ្រោះមានសិទ្ធិប្តឹងឧទ្ធរណ៍ចំពោះសាលក្រមរបស់តុលាការដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញបាន ។ ពាក្យថា “ប្តឹងឧទ្ធរណ៍” មានន័យថាជាដំណើរការពិនិត្យមើលឡើងវិញរបស់តុលាការថ្នាក់ខ្ពស់ជាងទៅលើសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមដើម្បីរកឲ្យឃើញថាតើសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមត្រឹមត្រូវដែរឬយ៉ាងណា ។ ប្រសិនបើរកឃើញថាមិនត្រឹមត្រូវ តុលាការថ្នាក់ខ្ពស់ជាងអាចបដិសេធសេចក្តីរបស់តុលាការថ្នាក់ក្រោម ។

ច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌថ្មី ក៏បានអនុញ្ញាតឲ្យជនរងគ្រោះសុំទៅព្រះរាជអាជ្ញាឲ្យកសាងសំណុំរឿងប្រឆាំងបុគ្គលមួយចំនួនបានផងដែរ ។ ព្រះរាជអាជ្ញាគឺជាបុគ្គលដែលទទួលខុសត្រូវក្នុងការស៊ើបសួរទៅលើជនល្មើស ចោទប្រកាន់ទៅលើជនល្មើសទាំងនោះនៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញ

និងរកឲ្យឃើញថាជនល្មើសទាំងអស់នោះពិតជាបានប្រព្រឹត្តបទល្មើសអ្វីមួយពិតប្រាកដមែនឬទេ ។ នៅពេលណាដែលព្រះរាជអាជ្ញាធ្វើបណ្តឹងអាជ្ញាប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យហើយនោះ ជនរងគ្រោះណាម្នាក់ដែលទទួលរងគ្រោះផ្ទាល់ពីមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យរូបណាមួយជាក់លាក់អាចដាក់ពាក្យប្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញដើម្បីទាមទារសំណងចំពោះការខូចខាតដែលបង្កឡើងដោយបុគ្គលមេដឹកនាំជាន់ខ្ពស់រូបនោះ ។ ជនរងគ្រោះដែលធ្វើបណ្តឹងរបៀបនេះហៅថា "ភាគីនៃបណ្តឹងរដ្ឋប្បវេណី" ។ បើយោងតាមច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌឆ្នាំ១៩៩៣ ប្រជាជនកម្ពុជាអាចដាក់ពាក្យប្តឹងទៅដល់អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបាន ដើម្បីទាមទារសំណងជំងឺចិត្តដែលខ្លួនមានបងប្អូនស្លាប់ ដរាបណាខ្លួនមានសិទ្ធិស្របច្បាប់ដើម្បីនឹងធ្វើជាតំណាងឲ្យបងប្អូនរបស់ខ្លួនដែលស្លាប់បាត់បង់ជីវិតនោះ ។ ឧទាហរណ៍ ឪពុកអាចមានសិទ្ធិស្របច្បាប់ទៅលើកូនរបស់ខ្លួន ពីព្រោះគាត់ជាឪពុកត្រូវបានច្បាប់តម្រូវឲ្យចិញ្ចឹមបីបាច់ថែរក្សាកូនៗ ។ អាស្រ័យហេតុនេះឪពុកអាចដាក់ពាក្យប្តឹងជំនួសឲ្យកូនរបស់ខ្លួនដែលទទួលរងនូវការសម្លាប់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ។

ជាការសំខាន់ណាស់ដែលគួរចងចាំថា មិនមែនជនរងគ្រោះគ្រប់រូបអាចដាក់ពាក្យប្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញដើម្បីទាមទារសំណងជំងឺចិត្តបានគ្រប់ៗគ្នានោះទេ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាត្រូវបានបង្កើតឡើងដើម្បីវិនិច្ឆ័យសេចក្តីលើបណ្តឹងអាជ្ញាប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមានចំនួនបុគ្គលិកធ្វើការតាមការកំណត់មួយសម្រាប់ពេលវេលាជាក់លាក់កំណត់មួយដើម្បីធ្វើការលើរឿងក្តីអស់ទាំងនេះ ។ បុគ្គលិកដែលធ្វើការនៅក្នុងអង្គជំនុំជម្រះវិសាមញ្ញអាចធ្វើការងារតែទៅលើបណ្តឹងអាជ្ញាប៉ុណ្ណោះហើយអាចពិនិត្យទៅលើបណ្តឹងរដ្ឋប្បវេណីមួយចំនួនតូចដែរ ។ ប្រសិនបើអង្គជំនុំជម្រះវិសាមញ្ញព្យាយាមធ្វើការងារទៅលើបណ្តឹងទាំងអស់វិញ អង្គជំនុំជម្រះវិសាមញ្ញមិនអាចនឹងធ្វើការងាររចប់សព្វគ្រប់បានឡើយ ។ ក៏ប៉ុន្តែជនរងគ្រោះអាចរៀបចំជាក្រុមៗដើម្បីដាក់ពាក្យប្តឹងជារួមទៅអង្គជំនុំជម្រះវិសាមញ្ញដើម្បីទាមទារសំណងជំងឺចិត្តពីមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមខ្លះ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងពិចារណាអំពីថាតើនឹងជួយដល់ជនរងគ្រោះយ៉ាងដូចម្តេច ហើយរហូតមកដល់ពេលនេះគឺនៅពុំទាន់បានធ្វើការសម្រេចជាចុងក្រោយនៅឡើយទេ ។

## សិទ្ធិមានអ្នកតំណាង

ជនរងគ្រោះអាចមានមេធាវីឲ្យជួយខ្លួនក្នុងការដាក់ពាក្យប្តឹងទៅអង្គជំនុំជម្រះវិសាមញ្ញ ។





ប្រសិនបើជនរងគ្រោះដាក់ស្នើរៀបចំទៅជាក្រុមៗ ក្រុមជនរងគ្រោះនេះអាចពឹងពាក់មេធាវីម្នាក់ជួយខ្លួនបាន ។ របៀបនេះអាចជួយឲ្យអង្គជំនុំជម្រះវិសាមញ្ញអាចពិនិត្យលើបណ្តឹងរដ្ឋប្បវេណីបានកាន់តែច្រើន ។

## សិទ្ធិទទួលបានការការពារ

ជនរងគ្រោះមួយចំនួន នឹងត្រូវបានស្នើសុំឲ្យមកឆ្លើយបំភ្លឺជាសាក្សីនៅចំពោះអង្គជំនុំជម្រះវិសាមញ្ញ ។ ជនរងគ្រោះ "ឆ្លើយបំភ្លឺ" នឹងអញ្ជើញចូលទៅក្នុងតុលាការហើយឆ្លើយបំភ្លឺនូវការពិតទៅតាមការចោទសួររបស់តុលាការអំពីអ្វីដែលជនរងគ្រោះបានឃើញនិងពាក់ទងទៅនឹងឧក្រិដ្ឋកម្មដែលបានកើតឡើង ។ តាមវិធីនេះហើយដែលហៅថា ជនរងគ្រោះផ្តល់ភ័ស្តុតាងនៅចំពោះមុខតុលាការ ។

ជនរងគ្រោះអាចមានព្រួយបារម្ភនៅពេលដែលមកឆ្លើយបំភ្លឺនៅចំពោះមុខតុលាការ ។ ជនរងគ្រោះព្រួយបារម្ភថា អាចមានការព្យាយាមមិនឲ្យខ្លួននិយាយនៅចំពោះមុខតុលាការ ។ ក៏ប៉ុន្តែអង្គជំនុំជម្រះវិសាមញ្ញនឹងការពារសាក្សីទាំងឡាយដែលអញ្ជើញឲ្យមកនិយាយតាមវិធីមួយចំនួន ។ ជាដំបូងជនរងគ្រោះនឹងអាចនិយាយជាមួយសហចៅក្រម មេធាវី និងចុងចោទ ដោយពុំមាននរណាម្នាក់ក្រៅពីនេះផ្សេងទៀតចូលរួមស្តាប់ឡើយ ។ របៀបនេះហៅថា "នីតិវិធីជំនុំជម្រះក្តីដោយសម្ងាត់" ។ ប្រសិនបើជនរងគ្រោះឆ្លើយតាមរបៀបនេះ អ្នកដែលចូលរួមស្តាប់សវនាការនឹងមិនអាចដឹងបានទេថានរណាមួយជាសាក្សី ហើយសាក្សីនឹងពុំសូវមានការព្រួយបារម្ភអំពីការគំរាមកំហែងអ្វីទាំងអស់ ។ ច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាចែងថា អង្គជំនុំជម្រះវិសាមញ្ញអាចប្រើប្រាស់វិធីច្រើនផ្សេងទៀតដើម្បីការពារសាក្សី ។ អង្គជំនុំជម្រះវិសាមញ្ញគួរតែព្យាយាមការពារជនរងគ្រោះបន្ទាប់ពីបានឆ្លើយបំភ្លឺនៅចំពោះតុលាការរួចហើយ ធ្វើដូច្នេះជនរងគ្រោះនឹងពុំមានបញ្ហាបន្ទាប់ពីខ្លួនវិលត្រឡប់មកផ្ទះសម្បែងវិញ ។ អង្គជំនុំជម្រះវិសាមញ្ញប្រហែលជាអាចសម្រេចផ្សេងពីនេះថែមទៀត ដើម្បីការពារសាក្សីនៅក្នុងកំឡុងពេលប៉ុន្មានខែខាងមុខនេះក៏អាចថាបាន ។

អង្គការក្រៅរដ្ឋាភិបាលមួយចំនួននៅប្រទេសកម្ពុជានឹងអាចជួយជនរងគ្រោះតាមរូបភាពផ្សេងៗគ្នាជាច្រើនទៀត ។ អង្គការទាំងនោះអាចជួយការពារជនរងគ្រោះ ។ ក្រៅពីជួយការពារជនរងគ្រោះ អង្គការទាំងនោះអាចជួយផ្តល់ប្រឹក្សានិងសេវាចាំបាច់សំខាន់ៗដល់ជនរងគ្រោះបានច្រើនទៀតផង ។

## សំណងជំងឺចិត្ត

អនុលោមតាមច្បាប់កម្ពុជា ជនរងគ្រោះអាចដាក់ពាក្យប្ដឹងទៅអង្គជំនុំជម្រះវិសាមញ្ញដើម្បីទាមទារសំណងជំងឺចិត្តដែលខ្លួនបានបាត់បង់ខូចខាត ។ នេះហើយដែលជាគោលបំណងចង់ធ្វើជាភាគីរដ្ឋប្បវេណី ហើយអ្វីដែលទទួលបាននេះហៅថា "សំណងជំងឺចិត្ត" ។ ជាថ្មីម្ដងទៀត ដោយសារតែមានជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យជាច្រើនលាននាក់ដូច្នេះ វាមានការលំបាកខ្លាំងណាស់ក្នុងការដែលជនរងគ្រោះម្នាក់ៗទាមទារនូវសំណងជំងឺចិត្តជាលុយកាក់ ។ ទំនងជាថាជនរងគ្រោះប្រមូលផ្ដុំគ្នាជាក្រុមគឺអាចទាមទារសំណងជំងឺចិត្តជាលុយកាក់រួមគ្នាបាន ហើយលុយកាក់នោះឯងនឹងត្រូវយកទៅប្រើប្រាស់ជាប្រយោជន៍សមូហភាពរួមគ្នានៅក្នុងក្រុមនោះដូចជាសម្រាប់ការសិក្សានិងការចងចាំជាដើម ។ ក៏ប៉ុន្តែនេះគឺគ្រាន់តែជាការគិតទុកជាមុនប៉ុណ្ណោះទេ ហើយអាចថាអង្គជំនុំជម្រះវិសាមញ្ញនឹងមិនអនុញ្ញាតឲ្យជនរងគ្រោះប្ដឹងទាមទារសំណងជំងឺចិត្តក៏អាចថាបានដែរ ។

## សេចក្ដីសន្និដ្ឋានៈ យុត្តិធម៌ និងការផ្សះផ្សារបួសស្នាម

ជនរងគ្រោះសមនឹងទទួលបានយុត្តិធម៌ចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ និង១៩៧៩ ។ អំពើគ្រប់យ៉ាងរួមទាំងគោលនយោបាយរបស់ខ្មែរក្រហមបានបង្កនូវការឈឺចាប់ដែលមិនអាចវាស់ស្ទង់បានទៅលើប្រជាជនកម្ពុជា ។ ឥឡូវនេះអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាបានធ្វើកិច្ចការរបស់ខ្លួនយ៉ាងសកម្ម ជនរងគ្រោះនឹងមានឱកាសចូលរួមជាបណ្ដើរៗ ។ ជនរងគ្រោះមួយចំនួននឹងអាចចូលស្ដាប់ការបើកសវនាការដោយផ្ទាល់ ហើយជនរងគ្រោះទាំងអស់គ្នានឹងអាចស្វែងយល់អំពីអ្វីដែលបានកើតឡើងនៅក្នុងពេលបើកសវនាការជាក់ជាមិនខាន ។ ចំពោះជនរងគ្រោះដែលចូលរួមយ៉ាងដូច្នេះ ទាំងច្បាប់ក្នុងស្រុកដែលនៅជាធរមាន ទាំងច្បាប់ស្ដីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាដើម្បីកាត់សេចក្ដីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ និង១៩៧៩ នឹងធ្វើការសម្រេចថាតើជនរងគ្រោះអាចចូលរួមបានតាមវិធីណា ហើយការពារសិទ្ធិរបស់ជនរងគ្រោះបានតាមវិធីណា ។ តាមរបៀបនេះហើយ ដែលជនរងគ្រោះអាចដើរតួយ៉ាងសំខាន់ក្នុងការជួយរកយុត្តិធម៌ប្រឆាំងនឹងមេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម ។ តាមការសង្ឃឹមទុក ការចូលរួមរបស់ជនរងគ្រោះ នឹងជួយឲ្យមានការផ្សះផ្សារបួសស្នាមនៅសេសសល់ដែលបង្កឡើងដោយរបបខ្មែរក្រហម ព្រមទាំងជួយឲ្យប្រជាជនកម្ពុជាបោះជំហានទៅមុខឆ្ពោះទៅរកអនាគតរុងរឿងត្រចះត្រចង់ ។





# សំណងជំងឺចិត្តចំពោះជនរងគ្រោះនៃរបបខ្មែរក្រហម

វ៉ាន់ថាន់ ពៅដារ៉ា

សូមអនុញ្ញាតឲ្យខ្ញុំបាទបានចែករំលែកការពិចារណារបស់ខ្ញុំទាក់ទិនទៅនឹងបញ្ហាសំណងជម្ងឺចិត្ត ។ សំណងជំងឺចិត្តដល់ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យ នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាគឺជាបញ្ហាមួយស្មុគស្មាញដែលមិនទាន់ត្រូវបានដោះស្រាយឲ្យជ្រះស្រឡះនៅឡើយ ។

បច្ចុប្បន្ននេះ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាកំពុងកសាងសំណុំរឿងចោទប្រកាន់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហម និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មដែលបានកើតឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ ក្នុងកាលៈទេសៈនេះ ការលើកឡើងអំពីសំណងជំងឺចិត្ត គឺពុំសូវជាទំនងឡើយ ពីព្រោះថាការលើកឡើងនេះអាចធ្វើឲ្យខូចដល់អត្ថន័យនៃយុត្តិធម៌ពិតប្រាកដ ប្រសិនបើពុំមានការពន្យល់ច្បាស់លាស់ទេនោះ ។



ប្រជាជនទស្សនាសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង

មានការលើកឡើងថា “តាមច្បាប់នៅប្រទេសមួយចំនួន ជនរងគ្រោះមិនត្រឹមតែទទួលបានយុត្តិធម៌ប៉ុណ្ណោះទេ ក៏ប៉ុន្តែថែមទាំងទទួលបានសំណងជំងឺចិត្តទៀតផង” ។ ការលើកឡើងបែបនេះអាចបំផ្លាញដល់ក្តីសង្ឃឹមរបស់ជនរងគ្រោះដែលចង់បានយុត្តិធម៌ ការផ្សះផ្សា និងនីតិរដ្ឋ (ធម្មាធិបតេយ្យ) ។ តាមការសង្កេតរបស់ខ្ញុំ ឃើញថាជនរងគ្រោះនៃរបបខ្មែរក្រហមភាគច្រើនទំនងជាមិនចង់រកលទ្ធភាពដើម្បីទទួលបានសំណងជំងឺចិត្តនោះទេ ផ្ទុយទៅវិញជនរងគ្រោះភាគច្រើនចង់ឃើញភាពយុត្តិធម៌ជាង ។

ជាការពិតណាស់ដែលថានៅក្នុងប្រព័ន្ធតុលាការរបស់ប្រទេសនៅអឺរ៉ុប ជនរងគ្រោះនៃឧក្រិដ្ឋកម្មអ្វីមួយ អាចប្តឹងទាមទារសំណងជំងឺចិត្តនៅក្នុងសវនាការព្រហ្មទណ្ឌបាន ។ នៅក្នុងប្រព័ន្ធច្បាប់ “ខមិនឡ” (ដែលច្រើនអនុវត្តនៅសហរដ្ឋអាមេរិកនិងចក្រភពអង់គ្លេស) ជនរងគ្រោះអាចធ្វើបណ្តឹងរដ្ឋប្បវេណីដើម្បីទាមទារសំណងជំងឺចិត្តដាច់ដោយឡែក ក៏ប៉ុន្តែឲ្យស្របជាមួយគ្នានឹងដំណើររឿងក្តីព្រហ្មទណ្ឌ ។ ទោះបីជាយ៉ាងនេះក្តី មានកត្តាជាច្រើនបង្ហាញថា វាពុំសូវជាទំនងសោះដែលនាំគ្នាលើកអំពីបញ្ហាសំណងជំងឺចិត្តនៅពេលនេះ ។

ទី១) មកដល់ពេលបច្ចុប្បន្ននេះ គឺពុំទាន់មានយុត្តិសាស្ត្រ (សេចក្តីសម្រេចតាមផ្លូវតុលាការ) ណាមួយពីមុនមកដែលនិយាយអំពីសំណងជំងឺចិត្តជាប្រាក់កាក់ដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មប្រល័យពូជសាសន៍នៅឡើយទេ ។

ទី២) ទាំងច្បាប់អន្តរជាតិ ទាំងច្បាប់ទំនៀមទម្លាប់អន្តរជាតិមានចែងតិចតួចអំពីសំណងជំងឺចិត្តដល់ជនរងគ្រោះនៃឧក្រិដ្ឋកម្មអន្តរជាតិ ដូចជាឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ តែទោះជាយ៉ាងនេះក៏ដោយ ច្បាប់អន្តរជាតិកំពុងតែធ្វើការដោះស្រាយបញ្ហាសិទ្ធិរបស់ជនរងគ្រោះឲ្យទទួលបាននូវ“សំណងជំងឺចិត្ត”ជាបណ្តើរៗហើយ ។ កិច្ចការនេះតម្រូវឲ្យចៅក្រមសម្រេចថាតើត្រូវគណនាការខូចខាតតាមរបៀបណា ព្រមទាំងសម្រេចទៀតថា តើត្រូវសងជំងឺចិត្តដល់ជនរងគ្រោះយ៉ាងដូចម្តេច ដែលកិច្ចការនេះតម្រូវឲ្យមានការពិចារណាយ៉ាងល្អិតល្អន់ទៅលើកត្តានានានៅជុំវិញឧក្រិដ្ឋកម្មដែលកើតឡើងនេះ ។ កិច្ចការនេះក៏តម្រូវឲ្យចៅក្រមមានគំនិតច្នៃប្រឌិតផងដែរក្នុងការរកវិធីណាមួយដែលផ្តល់សំណងជំងឺចិត្តមិនមែនជាប្រាក់កាក់ដល់ជនរងគ្រោះរាប់លាននាក់ ដូចជាសាងសង់បូជនីយដ្ឋានរំឭកវិញ្ញាណក្ខន្ធជនរងគ្រោះ ឬបង្កើតជាទិវានៃការចងចាំជាដើម ។

ទី៣) កិច្ចការកំណត់ចំនួនជនរងគ្រោះ និងគណនាសំណងជាសរុបសឹងតែមិនអាចធ្វើទៅរួចទេ ប្រសិនបើគិតអំពីពេលវេលាជាង២៧ឆ្នាំដែលបានកន្លងផុតទៅហើយនោះ ។ លើសពីនេះទៅទៀត





អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ទំនងជាគ្មានលទ្ធភាពក្នុងការផ្តល់សំណងដល់ជនរងគ្រោះទាំងអស់នៃរបបប្រល័យពូជសាសន៍នៅកម្ពុជាឡើយ ។

ទី៤) ក្នុងអំឡុងរបបកម្ពុជាប្រជាធិបតេយ្យ (ខ្មែរក្រហម) ប្រជាជនកម្ពុជារាប់លាននាក់បានស្លាប់បាត់បង់ជីវិត ហើយទ្រព្យសម្បត្តិជាច្រើនត្រូវខ្មែរក្រហមរឹបអូសនិងបំផ្លិចបំផ្លាញស្ទើរតែទាំងអស់ ។ អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាប្រហែលជាមិនអាចសម្រេចប្រគល់ទ្រព្យសម្បត្តិខាងលើស្ទើរតែទាំងអស់ឲ្យទៅម្ចាស់ដើមស្របច្បាប់វិញបានទេ ដោយហេតុថា ពេលវេលាបានកន្លងហួសទៅយូរលង់មកហើយ (ការផ្លាស់ប្តូរនិងផ្ទេរកម្មសិទ្ធិបានធ្វើឡើងជាច្រើនលើកច្រើនសា ហើយពីបុគ្គលម្នាក់ទៅបុគ្គលម្នាក់ទៀតរាប់មិនអស់) បើទោះបីជាអង្គជំនុំជម្រះវិសាមញ្ញប្រហែលជាអាចដោះស្រាយបានរឿងនេះក៏ដោយ ក៏មានចំនួនតិចតួចស្តួចស្តើងបំផុតដែរ ។

ទោះបីជាច្បាប់ស្តីពីការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាមិនបានចែងពីសំណងជំងឺចិត្តក៏ដោយ ប៉ុន្តែនេះមិនមែនមានន័យថា គ្មានមធ្យោបាយក្នុងការដោះស្រាយឲ្យមានសំណងទាល់តែសោះនោះទេ ។ មាត្រា៣៩ថ្មីនៃវិសោធនកម្មច្បាប់របស់អង្គជំនុំជម្រះវិសាមញ្ញបានចែងយោងដល់ការរឹបអូសទ្រព្យសម្បត្តិរបស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមដែលទទួលបានពីអំពើខុសច្បាប់ក្នុងរវាងឆ្នាំ១៩៧៥ និងឆ្នាំ១៩៧៩ ។ នៅក្នុងមាត្រានេះបញ្ជាក់ថា “ទ្រព្យសម្បត្តិដែលរឹបអូសបាននេះត្រូវប្រគល់ជូនរដ្ឋ” ។

មាត្រា៣៩ថ្មី បើកផ្លូវឲ្យមានលទ្ធភាពទទួលបាននូវសំណងជំងឺចិត្តនៅក្នុងក្របខ័ណ្ឌស្របច្បាប់របស់តុលាការ ។ អាស្រ័យហេតុនេះ ក្រោយពេលដែលរដ្ឋាភិបាលទទួលបានទ្រព្យសម្បត្តិឬលុយកាក់ដែលរឹបអូសហើយ ដូចដែលមានចែងក្នុងមាត្រា៣៩ថ្មី ជនរងគ្រោះអាចធ្វើសំណើបញ្ជូនទៅឲ្យរដ្ឋាភិបាលដើម្បីសុំឲ្យមានសំណងជំងឺចិត្តផ្សេងៗក្រោមរូបភាពជាសំណងនិមិត្តរូបដល់ខ្លួន ។ ឧទាហរណ៍ ជនរងគ្រោះអាចស្នើសុំឲ្យសាងសង់មជ្ឈមណ្ឌលព្យាបាលជំងឺផ្លូវចិត្តថ្នាក់ជាតិ ដោយផ្តល់សេវាព្យាបាលឥតគិតថ្លៃ ឬសាងសង់មជ្ឈមណ្ឌលអប់រំអំពីការប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មផ្សេងៗទៀតដែលច្បាប់អន្តរជាតិហាមប្រាម ។

សរុបសេចក្តីមកគឺថា ការស្វែងរកសំណងជំងឺចិត្តនៅក្នុងកាលៈទេសៈនេះអាចធ្វើឲ្យប្រជាជនកម្ពុជាងាកបេរចេញពីការយកចិត្តទុកដាក់ទៅលើបញ្ហាដ៏សំខាន់បំផុតដែលអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាអាចផ្តល់ជូនបាន គឺយុត្តិធម៌ដល់ជនរងគ្រោះរាប់លាននាក់ ដោយបញ្ចប់នូវនិទ្ទណ្ឌភាព (ភាពគ្មានទោស) របស់មេដឹកនាំជាន់ខ្ពស់ខ្មែរក្រហមនិងការកសាងនីតិរដ្ឋដ៏រឹងមាំមួយ ។

# ផែនទីរណ្តៅសាកសពនៃរបបកម្ពុជាប្រជាធិបតេយ្យ






# សារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ទួលស្លែង "អតីតមន្ទីរសន្តិសុខ ស-២១ របស់ខ្មែរក្រហម"

ឆាំង យុ

នៅក្នុងភាសាអង់គ្លេស ពាក្យ "ទួលស្លែង" ត្រូវបានស្គាល់ថា ជាកន្លែងដែលរបបកម្ពុជាប្រជាធិបតេយ្យ (របបខ្មែរក្រហម) យកមកធ្វើជាមន្ទីរឃុំឃាំងមួយ ដើម្បីដាក់អ្នកដែលប្រឆាំងនឹងអង្គការ ។ នៅក្នុងភាសាខ្មែរ ពាក្យ"ទួលស្លែង" គឺបានបង្កប់នូវអត្ថន័យមិនល្អរួចស្រេចទៅហើយ ។ វាប្រហែលជាភាពចៃដន្យដ៏ចម្លែកមួយដែលរបបខ្មែរក្រហមបានយកទីតាំងនេះធ្វើជាមន្ទីរឃុំឃាំង ។

យោងទៅតាមវចនានុក្រមខ្មែរដែលបោះពុម្ពដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ឆ្នាំ១៩៦៧ ពាក្យ "ទួល"គឺជានាមស័ព្ទ មានន័យថា "ទីតាំងដែលខ្ពស់ជាងតំបន់នៅជុំវិញ" ។ ពាក្យ "ស្លែង" អាចដើរតួនាទីជានាមផង និងជាគុណនាមផង ។ នៅពេលដែលពាក្យ"ស្លែង"ដើរតួជាគុណនាម វាមានន័យថា "ដែលឲ្យទោស" ឬ "ដែលនាំឲ្យទាស់" ឬ "ដែលជាសត្រូវនឹងរោគ" ។ នៅពេលពាក្យនេះដើរតួជានាម "ស្លែង" មានន័យថាជាដើមឈើដែលមានជាតិពុល ។ ដើមស្លែងមានពីរប្រភេទ ។ ប្រភេទទីមួយគឺ"ស្លែងធំ" ដែលមានដើមស្លឹក និងផ្លែធំៗ ។ ប្រភេទទីពីរគឺដើម"ស្លែងវល្លិ៍" ដែលជាស្លែងម្យ៉ាងមានផ្លែតូចៗ ។ តាមរយៈការពន្យល់ខាងលើ យើងអាចឃើញថា ន័យត្រង់របស់"ទួលស្លែង"មានន័យថា "ទួលដែលពុល ឬជាទួលមួយសម្រាប់ដាក់អ្នកដែលមានកំហុស ឬបង្កកំហុសចំពោះអង្គការ" ។

បើយោងទៅតាមឯកសារដែលរកឃើញដោយមជ្ឈមណ្ឌលឯកសារកម្ពុជា មន្ទីរស-២១ ត្រូវបានបង្កើតនៅទួលស្លែងក្នុងខែឧសភា ឆ្នាំ១៩៧៦ ។

ស-២១ ឬទួលស្លែង គឺជាមែកធាងដ៏សម្ងាត់បំផុតរបស់របបខ្មែរក្រហម ។ ស-២១គឺជាពាក្យកាត់របស់"មន្ទីរសន្តិសុខ២១" ។ ស-២១គឺជាស្ថាប័នសន្តិសុខដ៏សំខាន់របស់អង្គការដែលត្រូវបានរៀបចំឡើងជាពិសេសសម្រាប់សួរចម្លើយនិងសម្រាប់អ្នកដែលប្រឆាំងនឹងអង្គការ ។

ក្នុងឆ្នាំ១៩៦២ ស-២១គឺជាវិទ្យាល័យមួយដែលមានឈ្មោះថា "វិទ្យាល័យពញាយ៉ាត" ។ នៅក្នុងរបបលន់ នល់ សាលានេះបានប្តូរឈ្មោះទៅជា"វិទ្យាល័យទួលស្វាយព្រៃ" ។ សាលានេះមានអគារពីរខ្នង ធ្វើអំពីឈើ ប្រក់ស្បូវ ។ អគារទាំងនេះសាងសង់ឡើងមុនឆ្នាំ១៩៧០ជាសាលាបឋមសិក្សា ។ សព្វថ្ងៃអគារទាំងនេះត្រូវបានហៅថាជា "ទួលស្លែង" ដែលបង្កើតបានទៅជាផ្នែកមួយនៃសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង ។

ស-២១ ដែលស្ថិតនៅក្នុងសង្កាត់ទួលស្វាយព្រៃ២ ភាគខាងត្បូងនៃទីក្រុងភ្នំពេញ មានទីតាំងនៅលើផ្ទៃដីដែលមានផ្ទៃក្រឡា៦០០ម៉ែត្រ X ៤០០ម៉ែត្រ ។ នៅក្នុងអំឡុងរបបខ្មែរក្រហម កន្លែងនេះត្រូវបានហ៊ុមព័ទ្ធដោយរបងស័ង្កសីពីរជាន់និងមានដាក់ខ្សែភ្លើងយ៉ាងក្រាស់ពីលើរបងនេះដើម្បីការពារមិនឲ្យមានអ្នកលួចរត់ចេញពីមន្ទីរឃុំឃាំង ។ ផ្ទះដែលនៅជុំវិញអគារត្រូវបានប្រើប្រាស់ជាមន្ទីររដ្ឋបាល កន្លែងសួរចម្លើយនិងធ្វើទារុណកម្ម ។

ក) កងកម្លាំងនៅខាងក្នុង....................................១៤១នាក់

ខ) បុគ្គលិកមន្ទីរ..............................................១.១៤៨នាក់

គ) កងសួរចម្លើយ..................................................៥៤នាក់

ឃ) បុគ្គលិកទូទៅ............................................១.៣៧៧នាក់

ចំនួនអ្នកធ្វើការនៅក្នុងមន្ទីរស-២១សរុបគឺ១.៧២០នាក់ ។ ភាគច្រើននៃ “បុគ្គលិកទូទៅ” ត្រូវឃុំនៅព្រៃស ។

កងនីមួយៗចែកជាក្រុមតូចៗដែលមានសមាជិកជាក្មេងប្រុសស្រីអាយុចាប់ពី១០ឆ្នាំដល់១៥ឆ្នាំ ។ ក្មេងៗទាំងនេះត្រូវហ្វឹកហាត់ និងជ្រើសរើសដោយរបបខ្មែរក្រហមឲ្យទៅបំពេញការងារជាអ្នកយាមនៅស-២១ ។ ភាគច្រើននៃអ្នកទាំងនេះមុនដំបូងជាមនុស្សធម្មតា ប៉ុន្តែក្រោយមកភាពឃោរឃៅរបស់អ្នកទាំងនេះបានកើនឡើងជាលំដាប់ ។ អ្នកទាំងនេះមានចរិតសាហាវកោងកាចចំពោះអ្នកទោសនិងអ្នកដែលមានអាយុច្រើនជាងខ្លួន ។

មានមន្ទីរគ្រប់គ្រងពីរ ។ ទីមួយគឺជាមន្ទីររបស់ឌុច និងមួយទៀតជាមន្ទីរទទួលបន្ទុកសួរចម្លើយឯកសារនិងរដ្ឋបាលទូទៅ ។ អ្នកទោសដែលឈឺឬរបួសត្រូវព្យាបាលដោយពេទ្យនៅក្នុងបន្ទប់ឃុំឃាំងនីមួយៗ ។ ការព្យាបាលគឺធ្វើឡើងបីដងក្នុងមួយថ្ងៃ ។ គ្មានការថែទាំសុខភាពនៅក្នុងមន្ទីរឃុំឃាំងនេះទេ ។ បុគ្គលិកពេទ្យសុទ្ធតែមិនទទួលបានការបណ្តុះបណ្តាល ហើយភាគច្រើនជាក្មេងៗទៀត ។

ជនរងគ្រោះនៅក្នុងមន្ទីរឃុំឃាំងនេះគឺមកពីគ្រប់ផ្នែកទាំងអស់នៅទូទាំងប្រទេស ។ អ្នកទាំងនេះមានសញ្ជាតិផ្សេងៗគ្នាផងដែរដូចជា វៀតណាម ឡាវ ថៃ ឥណ្ឌា ប៉ាគីស្ថាន ចក្រភពអង់គ្លេស អាមេរិក កាណាដា ណូវែលហ្សេឡង់ និងអូស្ត្រាលី ប៉ុន្តែភាគច្រើនជាជនជាតិកម្ពុជា ។ អ្នកទោសដែលជាជនស៊ីវិលមានកម្មករ កសិករ វិស្វករ អ្នកបច្ចេកទេស បញ្ញវន្ត សាស្ត្រាចារ្យ គ្រូបង្រៀន និស្សិត និងសូម្បីតែរដ្ឋមន្ត្រី និងអ្នកការទូតក៏មានជាប់នៅក្នុងនោះដែរ ជាងនេះទៅទៀត សមាជិកគ្រួសារទាំងអស់របស់អ្នកទោសទាំងចាស់ទាំងក្មេង រួមទាំងទារក ត្រូវបានយកទៅទីនោះដើម្បីសម្លាប់ទាំងអស់ ។





បើយោងទៅតាមរបាយការណ៍របស់ខ្មែរក្រហមដែលបានរកឃើញនៅក្នុងបណ្ណសារដ្ឋានទួលស្លែង ចំនួនអ្នកទោសចេញនិងចូលចាប់ពីឆ្នាំ១៩៧៥ ដល់ខែមិថុនា ឆ្នាំ១៩៧៨ ត្រូវបានកត់ត្រានៅក្នុងបញ្ជី ។ ឯកសារខ្លះត្រូវបានបាត់បង់ ។ របាយការណ៍មួយបានប៉ាន់ស្មានចំនួនអ្នកទោសដូចខាងក្រោមនេះៈ

- ១៩៧៥.............................................១៥៤នាក់
- ១៩៧៦...........................................២.២៥០នាក់
- ១៩៧៧...........................................២.៣៣០នាក់
- ១៩៧៨...........................................៥.៧៦៥នាក់

តួលេខទាំងនេះសរុបទៅគឺ១០.៤៩៩នាក់ ។ របាយការណ៍នេះបានបញ្ជាក់ថា ចំនួនសរុបនេះគឺមិនទាន់រាប់បញ្ចូលនូវចំនួនកុមារចំនួន២.០០០នាក់ ដែលត្រូវសម្លាប់នៅក្នុងមន្ទីរស-២១នេះផងទេ ។

របាយការណ៍ផ្សេងៗបង្ហាញថានៅក្នុងឆ្នាំ១៩៧៧ និង១៩៧៨ ពេលខ្លះមន្ទីរឃុំឃាំងនេះដាក់អ្នកទោសពី១.២០០នាក់ ទៅ១.៥០០នាក់ ជាមធ្យម ។ រយៈពេលនៃការឃុំឃាំងគឺចាប់ពី២ទៅដល់៤ខែ ប៉ុន្តែអ្នកទោសនយោបាយសំខាន់ខ្លះត្រូវឃុំពី៦ទៅ៧ខែ ។

អ្នកទោសត្រូវឃុំឃាំងនៅក្នុងបន្ទប់តូចៗ និងត្រូវដាក់ខ្នោះជើងដោយច្រវាក់ភ្ជាប់ទៅនឹងជញ្ជាំង ឬទៅនឹងកម្រាលឥដ្ឋ ។ ជើងម្ខាងឬទាំងពីររបស់អ្នកទោសដែលត្រូវដាក់នៅក្នុងបន្ទប់ធំរួមជាប់ខ្នោះទៅនឹងរនុកដែកវែងឬខ្លី ។ រនុកដែកខ្លីមានប្រវែងពី០,៨ម៉ែត្ររហូតដល់១ម៉ែត្រ ធ្វើសម្រាប់ដាក់អ្នកទោសចំនួន៤នាក់ ។ រនុកដែកវែងមានប្រវែង៦ម៉ែត្រ ធ្វើសម្រាប់ដាក់អ្នកទោសពី២០ទៅ៣០នាក់ ។ អ្នកទោសត្រូវបានដាក់ភ្ជាប់ទៅនឹងរនុកដែក ដែលតម្រូវឲ្យអ្នកទោសត្រូវដេកទល់ក្បាលគ្នា ។

មុនដំបូង អ្នកទោសត្រូវបានដាក់នៅក្នុងបន្ទប់ដើម្បីថតរូប និងស្រង់ប្រវត្តិរូបពិស្តារតាំងពីក្មេងរហូតដល់ថ្ងៃដែលត្រូវចាប់ខ្លួន ។ បន្ទាប់មកអ្នកទោសត្រូវសម្រាតសម្លៀកបំពាក់ចេញទាំងអស់ទុកតែខោក្នុង ។ អ្នកទោសត្រូវដកហូតរបស់របរទាំងអស់ដែលនៅជាប់នឹងខ្លួន ។ អ្នកទោសត្រូវដេកដោយផ្ទាល់លើកម្រាលឥដ្ឋ ដោយមិនមានកន្ទេល មុង ឬភួយឡើយ ។

ម៉ោង៤ៈ៣០នាទីរៀងរាល់ព្រឹក អ្នកយាមបានប្រាប់អ្នកទោសទាំងអស់ឲ្យស្រាតខោចុះត្រឹមកជើងដើម្បីត្រួតពិនិត្យ ។ បន្ទាប់មក អ្នកទោសត្រូវបានប្រាប់ឲ្យធ្វើលំហាត់ប្រាណខ្លះដោយគ្រាន់តែលើកដៃនិងជើងដែលកំពុងជាប់ទៅនឹងរនុកដែកចុះឡើងៗរយៈពេលកន្លះម៉ោង ។

អ្នកយាមឆែកឆេរខ្លួនអ្នកទោស៤ដងក្នុងមួយថ្ងៃ ហើយជួនកាលគណៈគ្រួតពិនិត្យពីមន្ទីរសន្តិសុខបានធ្វើការឆែកឆេរពិសេសលើខ្លួនរបស់អ្នកទោសថែមទៀត ។ ក្នុងពេលត្រួតពិនិត្យម្ដងៗ អ្នកទោសត្រូវដាក់ដៃទៅក្រោយខ្នងនិងត្រូវលើកជើងឡើងដើម្បីឲ្យអ្នកយាមអាចត្រួតពិនិត្យមើលក្រែងខ្នោះជើងធូរពេក ។ ប្រសិនបើធូរពេក ខ្នោះជើងត្រូវប្ដូរថ្មី ។ អ្នកទោសត្រូវបន្ទោរបង់ដាក់ក្នុងកេះដែកនិងនោមដាក់ក្នុងធុងជ័រដែលដាក់នៅក្នុងបន្ទប់ឃុំឃាំងនោះ ។ មុនពេលបន្ទោរបង់ អ្នកទោសត្រូវសុំការអនុញ្ញាតពីអ្នកយាមជាមុន បើមិនដូច្នោះទេ អ្នកទោសនឹងត្រូវទទួលពិន័យពី២០ទៅ៣០រំពាត់ ។ នៅក្នុងបន្ទប់នីមួយៗមានក្ដារខៀនតូចមួយដែលមានសរសេរវិន័យ៩ចំណុចដែលអ្នកទោសត្រូវតែអនុវត្តតាមជាដាច់ខាត បើមិនដូច្នោះទេនឹងត្រូវទទួលទណ្ឌកម្ម ។ វិន័យទាំង៩ចំណុចនោះមានៈ

១) សួរអី ឆ្លើយហ្នឹង មិនបង្វែងសំណួររបស់អញ ។

២) មិនឲ្យដោះស្រាយ យកលេសនេះ លេសនោះតាមគំនិតឯងលាក់ ឬប្រកែកតមាត់មិនបានដាច់ខាត ។

៣) មិនឲ្យធ្វើល្ងង់ មិនយល់បញ្ហា ព្រោះឯងជាមនុស្សហ៊ានប្រឆាំងបដិវត្តន៍ ។

៤) សួរភ្លាម ឆ្លើយភ្លាម មិនដំអក់មួយនាទីឡើយ ។

៥) រឿងខុះខាត កំហុសបន្តិចបន្តួច ដូចជាសីលធម៌ ខូចនេះខូចនោះក៏មិនឲ្យនិយាយ រឿងខ្ទឹមសារបដិវត្តក៏មិនឲ្យនិយាយ ។

៦) រវើបុះឆក់ខ្សែភ្លើងមិនឲ្យស្រែកជាដាច់ខាត ។

៧) មិនឲ្យធ្វើអ្វីទាំងអស់ គឺអង្គុយស្ងៀមរង់ចាំបញ្ជាអញ អត់បញ្ជាកុំធ្វើ អញបញ្ជាអីធ្វើហ្នឹងភ្លាម ប្រកែកប្រិមប្រុមមិនបានទេ ។

៨) កុំយកលេសកម្ពុជាក្រោមបាំងមុខមាត់ក្បត់បដិវត្តន៍របស់អាឯងឲ្យសោះ ។

៩) គ្រប់បញ្ហាខាងលើមិនធ្វើតាមគឺមួយថ្ងៃៗរងរំពាត់ ខ្សែភ្លើងឆក់រាប់មិនឈ្នះទេ ប្រឆាំងវិន័យអញមួយចំណុចត្រូវរងរំពាត់១០រំពាត់ឬឆក់ខ្សែភ្លើង៥ឆាប់ ។

អ្នកទោសត្រូវតែគោរពវិន័យគ្រប់ចំណុចទាំងអស់ ទោះធ្វើអ្វីក៏ដោយ សូម្បីតែចង់ប្រែខ្លួន ក៏ត្រូវតែសុំការអនុញ្ញាតពីអ្នកយាមជាមុនដែរ ។ អ្នកដែលមិនគោរពតាមវិន័យទាំងនេះត្រូវវាយដំយ៉ាងធ្ងន់ធ្ងរ ។ ពេលងូតទឹក អ្នកយាមទាញទុយោទឹកមួយចូលតាមបង្អួចបន្ទប់ឃុំឃាំង រួចបាញ់ទឹកដាក់អ្នកទោសមួយសន្ទុះ ។ ជួនកាលអ្នកទោសបានមុជទឹកមួយដងក្នុងរយៈពេលពីរ ឬជួនកាលពីរសប្ដាហ៍ម្ដង ។ ស្ថានភាពរស់នៅដែលខ្វះអនាម័យបានបណ្ដាលឲ្យអ្នកទោសមានជំងឺឆ្លង ដូចជា កើតរមាស់ និងជំងឺផ្សេងៗទៀត ហើយមិនមានថ្នាំសង្កូវសម្រាប់ព្យាបាលទេ ។





# អំពើប្រល័យពូជសាសន៍ដែលអាក្រក់បំផុត ចំណាប់អារម្មណ៍របស់ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ចូសេហ្វ អេ មូស្សូមេលី ចំពោះអ្នកចូលរួមដំណើរទស្សនកិច្ចមកកាន់អង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា

សួស្ដី ខ្ញុំមានកិត្តិយសសូមស្វាគមន៍អស់លោក លោកស្រី ទាំងអស់គ្នាដែលបានមកកាន់គេហដ្ឋានរបស់ខ្ញុំនៅថ្ងៃនេះ ។ កាលពីប៉ុន្មានខែមុននេះ ជនរងគ្រោះនៃរបបកម្ពុជាប្រជាធិបតេយ្យក៏បានមកអង្គុយនៅកន្លែងដែលអស់លោក លោកស្រីកំពុងអង្គុយនេះដែរ ហើយខ្ញុំបានប្រាប់ពួកគាត់ពីរឿងឧក្រិដ្ឋកម្មធំជាងគេបំផុតមួយនេះ ប្រចាំសតវត្សរ៍ទី២០ ដែលមិនទាន់បានទទួលការជំនុំជម្រះសេចក្ដីនៅឡើយអស់រយៈកាល៣០ឆ្នាំមកហើយ ។ ដូចយើងបានដឹងរួចហើយក្នុងរយៈកាលចន្លោះពីថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ ពោលគឺមិនដល់រយៈពេល៤ឆ្នាំផង របបខ្មែរក្រហមបានធ្វើទារុណកម្ម បង្អត់អាហារ និងសម្លាប់រង្គាលជនរួមជាតិកម្ពុជារបស់ខ្លួនអស់ប្រមាណជាង២លាននាក់ ។ គ្មាននរណាម្នាក់មានសុវត្ថិភាពទេ នៅពេលនោះមិនថា ចាម វៀតណាម ព្រះសង្ឃ អ្នករស់នៅទីក្រុង អ្នកមានសញ្ញាប័ត្រ ឬអ្នកដែលពាក់វ៉ែនតា ។ អ្នកទាំងនេះនិងមនុស្សដទៃ



ជាច្រើនទៀត រួមជាមួយនឹងគ្រួសាររបស់គេផង ត្រូវបានសម្លាប់យ៉ាងវេទ្គាលនៅក្នុងអំពើប្រល័យពូជសាសន៍មួយដែលអាក្រក់បំផុត និងមិនដែលមានពីមុនមក ។

ទោះជាយ៉ាងណាក៏ដោយ អ្នកខ្លះបាននិយាយថា អំពើឧក្រិដ្ឋទាំងនោះកើតឡើងយូរមកហើយ ហើយយើងគួរតែឈប់រំពុកអំពីអតីតកាលនេះ ។ គេនិយាយថា យើងគួរក្រឡេកមើលទៅអនាគត និងមិនគួរចំណាយថវិកាសន្ធឹកសន្ធាប់បែបនេះទៅលើសាលាជំនុំជម្រះក្តីនេះឡើយ ហើយគេនិយាយទៀតថា ថវិកានេះ គួរតែយកទៅប្រើប្រាស់ដើម្បីទិញស្បៀងអាហារ ឬផ្តល់ការថែទាំសុខភាពដល់អ្នកជំងឺវិញល្អជាង ។ ជាការពិតណាស់ អ្នកក្រគួរតែទទួលបានស្បៀងអាហារ ហើយអ្នកឈឺគួរតែទទួលបានការថែទាំសុខភាព ។ តើប៉ុណ្ណឹងគ្រប់គ្រាន់ឬទេ? តើយើងត្រូវការតែប៉ុណ្ណឹងទេឬ? តើរឿងសំខាន់មានតែត្រឹមការស្រេកឃ្លានស្បៀងអាហារទេឬ?

ឃ្លាមួយក្នុងព្រះគម្ពីរសាសនាគ្រិស្តបាននិយាយថាៈ មនុស្សមិនមែនរស់ដោយសារតែនំប៉័ងមួយមុខនោះទេ ។ យើងទាំងអស់គ្នាអាចយល់បានអំពីអត្ថន័យរបស់ឃ្លានេះ ពោលគឺមានន័យថា យើងមិនមែនជាសត្វមួយប្រភេទដែលមានការស្រេកឃ្លានអាហារ ដូចសត្វធាតុនោះទេ ។ អាហារតែមួយមុខមិនអាចបំពេញការស្រេកឃ្លានរបស់យើងបានទេ ។ មនុស្សគឺជាសត្វលោកដែលមានវិញ្ញាណ និងសីលធម៌ ។ តើមានអ្នកដែលនិយាយថា យើងមិនគួរមានវត្តអារាមទេ? តើមានអ្នកដែលនិយាយថាយើងគួរតែរុះរើវិហារសាសនាគ្រឹស្ត និងវិហារសាសនាអ៊ីស្លាមចេញដើម្បីយកថវិកាទាំងនោះទៅផ្គត់ផ្គង់ស្បៀងអាហារដល់អ្នកដែលកំពុងតែស្រេកឃ្លានទៅវិញដែរឬទេ? ភាគច្រើននៃពួកយើងទាំងអស់គ្នាដឹងថា យើងមានការស្រេកឃ្លានផ្នែកផ្លូវចិត្ត ដែលគេគួរតែបំពេញ ហើយយើងដឹងដែរថា វត្តអារាម និងព្រះវិហារគ្រិស្តសាសនា ជួយបំពេញការស្រេកឃ្លាននោះ ។

មនុស្សស្រេកឃ្លានអ្វីផ្សេងទៀត យ៉ាងហោចណាស់ក៏សំខាន់ស្មើនឹងអាហារដែរ ។ យើងស្រេកឃ្លានយុត្តិធម៌ ។ យើងមិនទទួលបានយុត្តិធម៌យូរមកហើយ ។ អំពើប្រល័យពូជសាសន៍នៅកម្ពុជាជាករណីតែមួយគត់ដែលមិនទាន់ឃើញមានការផ្តន្ទាទោសជនដែលជាប់ចោទពីការកាត់ទោសឧក្រិដ្ឋកម្មដែលបានប្រព្រឹត្ត ។ ប៉ុន្តែយុត្តិធម៌របៀបនេះមិនបានកើតមានទេនៅក្នុងប្រទេសកម្ពុជា ។

អ្នកខ្លះលើកឡើងថា ការចំណាយថវិកាដែលកំពុងខ្សត់ទៅលើបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងកាលពី៣០ឆ្នាំមុន គឺជារឿងដែលគួរឲ្យអស់សំណើច ប៉ុន្តែខ្ញុំសង្ឃឹមថាប្រជាជនខ្មែរភាគច្រើននឹងមិនយល់ស្របតាមការអះអាងនេះទេ ។ នៅកម្ពុជាអ្នកទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ ជាទូទៅកំពុងរស់នៅដោយមានសុវត្ថិភាពនិងសេរីភាពយ៉ាងសម្បូរសប្បាយ នៅក្នុងចំណោមមនុស្សដែលពួកគេធ្វើបាប ។ មិនមានគ្រួសារណាមួយនៅកម្ពុជាដែលមិនរងការប៉ះពាល់ដោយសារអំពើប្រល័យ





ពូជសាសន៍ទេ ។ របបខ្មែរក្រហមបានប្រកាសថា ខ្លួននឹងនាំប្រទេសកម្ពុជាទៅកាន់ឆ្នាំសូន្យ ហើយរបបនេះពិតជាបានរក្សាពាក្យសន្យានោះមែន ។ សាមសិបឆ្នាំក្រោយមកប្រទេសកម្ពុជានៅតែមានការបាត់បង់ និងបែកបាក់ដដែល ។

ការបែកបាក់របស់ប្រទេសកម្ពុជាមិនមែនត្រឹមតែផ្នែកនយោបាយ និងសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែបានប៉ះពាល់ដល់ទឹកចិត្ត និងស្មារតីផងដែរ ។ គុណវិបត្តិនៃប្រទេសកម្ពុជានៅក្នុងសម័យនេះរាប់តាំងពីការជួញដូរមនុស្សរហូតដល់ការជួញដូរថ្នាំញៀន ពីការឆក់ប្លន់ធនធានធម្មជាតិ និងសម្បត្តិវប្បធម៌រហូតដល់អំពើពុករលួយដែលរីករាលដាលនៅគ្រប់លំដាប់ថ្នាក់ទាំងអស់របស់រដ្ឋាភិបាល គុណវិបត្តិទាំងនេះកាន់តែធ្ងន់ធ្ងរទៅៗ ដោយសារតែការខកខានរបស់យើងក្នុងការនាំយកមេដឹកនាំខ្មែរក្រហមមកជំនុំជម្រះទោស ។ វប្បធម៌និទ្ទណ្ឌភាពដែលយើងឃើញមាននៅទូទាំងប្រទេសកម្ពុជាសព្វថ្ងៃនេះមានប្រភពពីជំនឿរបស់ប្រជាជនកម្ពុជាដែលជឿថា វាមិនដែលមានបទឧក្រិដ្ឋណាធំធេងដែលត្រូវតែផ្តន្ទាទោសនោះទេ និងថាអ្វីៗដែលប្រជាពលរដ្ឋកម្ពុជាធ្វើគឺអាចទទួលយកបានទាំងអស់ ព្រោះថាទង្វើទាំងនោះ បើទោះបីជាអាក្រក់យ៉ាងណាក៏មិនដល់ថ្នាក់អាក្រក់ជាងអ្វីដែលរបបខ្មែរក្រហមបានប្រព្រឹត្តដែរ ហើយអ្នកប្រព្រឹត្តទាំងនោះនៅតែរួចខ្លួនពីសំណាញ់ច្បាប់ ។

វានឹងនៅតែមានឧបសគ្គធំៗទៅលើដំណើរជឿនលឿនទៅមុខ និងកំណែទម្រង់របស់ប្រទេសកម្ពុជា លុះត្រាតែមានការផ្តល់យុត្តិធម៌នៅក្នុងកម្រិតណាមួយ ។ ប៉ុន្តែឧក្រិដ្ឋជនទាំងនោះកាន់តែមានវ័យចាស់ជរាណាស់ទៅហើយ ហើយមួយទសវត្សរ៍ទៀត អ្នកទាំងនេះទំនងជាស្លាប់យ៉ាងស្ងប់ស្ងាត់ និងដោយសុខសាន្ត ។ តាម៉ុកទើបតែស្លាប់សប្តាហ៍មុននេះ ។ ការស្លាប់នេះ ដែលបានឆក់យករួចហើយនូវជីវិត និងសុភមង្គលពីប្រជាជនខ្មែរជាច្រើន នៅពេលនេះទៀតបានឆក់យកពីពួកគេម្តងទៀតនូវឱកាសទទួលបានយុត្តិធម៌ ។ តើការស្រេកឃ្លានយុត្តិធម៌របស់យើងអាចបំពេញយ៉ាងដូចម្តេច បើតុលាការមិនបន្តការងាររបស់ខ្លួន? បើតុលាការនៅតែពន្យារពេលតទៅទៀត? បើជនដែលនៅតែអាចរស់នៅរហូតដល់ចាស់ស្លាប់ដោយសុខសាន្ត ដោយមិនបានទទួលស្គាល់ចំពោះអំពើឧក្រិដ្ឋរបស់ខ្លួន ឬទទួលខុសត្រូវចំពោះអំពើដ៏គួរឲ្យខ្លាចដែលពួកគេប្រព្រឹត្តមកលើប្រជាជនកម្ពុជាដែលជាជនរួមជាតិរបស់ពួកគេ?

អ្នកទាំងឡាយដែលបានស្លាប់ និងអ្នកទាំងឡាយដែលបានរងនូវការឈឺចាប់ៈ ការស្លាប់និងការឈឺចាប់របស់ពួកគេត្រូវការយុត្តិធម៌និងភាពស្ងប់ស្ងាត់ ។ ជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍សមនឹងទទួលបានយុត្តិធម៌ ហើយជនរងគ្រោះដោយអំពើប្រល័យពូជសាសន៍ទាមទារយុត្តិធម៌ ។ ប្រជាជនកម្ពុជាត្រូវការបំពេញសេចក្តីស្រេកឃ្លានយុត្តិធម៌របស់ពួកគេ ។



មជ្ឈមណ្ឌលឯកសារកម្ពុជា
"តុលាការកាត់ទោសមេដឹកនាំខ្មែរក្រហម"
Documentation Center of Cambodia
Searching for the Truth
DC-Cam ♦ 66 Preah Sihanouk Blvd. ♦ P.O.Box 1110 ♦ Phnom Penh
Tel: (855-23) 211-875 ♦ Fax: (855-23) 210-358 ♦ dccam@online.com.kh




មជ្ឈមណ្ឌលឯកសារកម្ពុជា
Documentation Center of Cambodia
Searching for the Truth